អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**គណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង**
Rules and Procedure Committee
Comité de Procédure

# លិខិតអន្តរការិយាល័យ

កាលបរិច្ឆេទ : ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១២
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

**ពី:** ឯកឧត្តម គង់ ស្រ៊ឹម
ប្រធានគណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង (“RPC”);

**ជូនចំពោះ:** ចៅក្រម **Laurent KASPER-ANSERMET**
សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ

**ចម្លងជូន:** សមាជិក RPC

**កម្មវត្ថុ:** ចម្លើយតបទៅនឹងកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១២

កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ៥១ ដល់កថាខណ្ឌ ៥៤ លើកឡើងថា ការបដិសេធរបស់គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងចំពោះសំណើសុំធ្វើវិសោធនកម្មរបស់លោក បង្ហាញពី “អវិភាពដែលសំដែងឡើងដោយបុគ្គលិកជាតិ នៅ អ.វ.ត.ក” ចំពោះចៅក្រម Kasper-Ansermet។ គណៈកម្មាធិការបដិសេធចំពោះការលើកឡើងថា អវិភាព ចំពោះចៅក្រម Kasper-Ansermet គឺជាមូលហេតុនៃការចេញសេចក្តីសម្រេចរបស់ខ្លួន និងសូមធ្វើការបំភ្លឺដូចខាង ក្រោម ៖

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

គណៈកម្មាធិការមានសមាជិកចំនួន ៩ រូប ក្នុងនោះមានចៅក្រមអន្តរជាតិចំនួន ៤ រូប។ យោងតាមវិធាន ២០(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) "គណៈកម្មាធិការត្រូវទទួល និងពិចារណាលើសំណើសុំធ្វើវិសោធនកម្ម វិធានផ្ទៃក្នុងទាំងនេះ និងរៀបចំសេចក្តីព្រាងស្នើសុំធ្វើវិសោធនកម្មសម្រាប់ពិភាក្សានៅក្នុងកិច្ចប្រជុំពេញអង្គ។ ក្នុង គោលដៅនេះ គណៈកម្មាធិការត្រូវជួបប្រជុំ តាមការចាំបាច់ តាមគំនិតផ្តួចផ្តើមរបស់ប្រធាន។ កិច្ចប្រជុំរបស់ គណៈកម្មាធិការត្រូវធ្វើជាសម្ងាត់"។ យោងតាមវិធាន ៣(២) នៃវិធានផ្ទៃក្នុង "សំណើសុំធ្វើវិសោធនកម្មដែលបញ្ជូន ពីគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ត្រូវដាក់ជូនកិច្ចប្រជុំពេញអង្គ [...]"។

យោងតាមវិធានទាំងនេះ ចាប់តាំងពីការបង្កើតរួចមក គណៈកម្មាធិការមានតួនាទីជាស្ថាប័នត្រួតពិនិត្យនៃសម័យ ប្រជុំពេញអង្គ ដោយគ្មានការជំទាស់ណាមួយត្រូវបានលើកឡើងក្នុងសម័យប្រជុំពេញអង្គទាក់ទងនឹងមុខងារនេះឡើយ។ ការជូនដំណឹងជាផ្លូវការដល់ការិយាល័យនីមួយៗ ដែលស្នើសុំធ្វើវិសោធនកម្មលើលទ្ធផលនៃការពិចារណារបស់ គណៈកម្មាធិការ និងមូលហេតុនៃការពិចារណារបស់ខ្លួន ដែលរួមទាំងមតិជំទាស់ដែលអាចកើតមានផង ពុំមានចែង នៅក្នុងវិធានផ្ទៃក្នុង និងក៏ពុំធ្លាប់អនុវត្តនោះដែរ ដើម្បីសន្សំពេលវេលា និងធនធាន។ គណៈកម្មាធិការបានពិនិត្យ ពិចារណាសំណើសុំរបស់ចៅក្រម Kasper-Ansermet ដោយអនុលោមតាមគោលការណ៍ដូចគ្នាដែលត្រូវអនុវត្ត ចំពោះសំណើទាំងអស់ និងដោយគ្មានអរិភាព ឬការរើសអើងអ្វីសោះឡើយ។ ហេតុដូច្នេះ ការចោទប្រកាន់អំពីភាព មិនប្រក្រតីផ្នែកនីតិវិធីពីសំណាក់គណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង ដែលមាននៅក្នុងកំណត់សម្គាល់នេះមិនមាន មូលដ្ឋានឡើយ។